អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
United Nations in Cambodia

# ទស្សនៈ/វិចារណកថា ៖ សប្តាហ៍មោទនភាព និង ទិវាអន្តរជាតិប្រឆាំងនឹងការស្អប់ខ្ពើមមនុស្សស្រឡាញ់ភេទដូចគ្នានិងមនុស្សប្តូរភេទ ឆ្នាំ ២០១៤

## សមភាព និង ភាពចម្រុះនៅក្នុងបេះដូងនៃសប្តាហ៍មោទនភាព

*ក្លែរ វ៉ាន់ដឺវ៉ារែន*

ថ្មីៗនេះនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិនៅក្នុងទីក្រុងសូជីអគ្គលេខាធិការអង្គការសហប្រជាជាតិ **បានគីមូន** បានប្រកាន់យកជំហរប្រឆាំងនឹងការស្អប់ខ្ពើមមនុស្សស្រឡាញ់ភេទដូចគ្នា និងមនុស្សប្តូរភេទដោយប្រកាសថា"យើងទាំងអស់គ្នាត្រូវតែបញ្ចេញសំឡេងរបស់យើងប្រឆាំងនឹងការវាយប្រហារមកលើមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ ឬមនុស្សភេទពីរ។ យើងត្រូវតែប្រឆាំងនឹង ការចាប់ខ្លួន ការដាក់ពន្ធនាគារ និងការហាមឃាត់ដែលមានលក្ខណៈរើសអើងដែលពួកគេជួបប្រទះ។ ការស្អប់ខ្ពើមទោះក្នុង រូបភាពណាក៏ដោយ មិនត្រូវកើតមានឡើយនៅក្នុងសតវត្សទី២១ នេះ។"

នៅខណៈពេលដែលយើងប្រារព្ធ **សប្តាហ៍មោទនភាព** នៅក្នុងសប្តាហ៍នេះនៅមុនទិវាអន្តរជាតិប្រឆាំងនឹងការស្អប់ខ្ពើមមនុស្សស្រឡាញ់ភេទដូចគ្នានិងមនុស្សប្តូរភេទនៅថ្ងៃស្អែក សារនេះរំលឹកយើងអំពីភាពចាំបាច់ដែលត្រូវលើកកម្ពស់ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបដោយមិនគិតពីទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេឡើយ។វាគឺជាសារមួយដែលគ្រួសារអង្គការសហប្រជាជាតិគាំទ្រយ៉ាងមុតមាំដោយផ្អែកលើគុណតម្លៃខាងក្នុងនៃភាពចម្រុះនិងសារៈសំខាន់ចំពោះការអភិវឌ្ឍដែលមានលក្ខណៈរួមបញ្ចូលនិងមានចីរភាព។

នៅដើមឆ្នាំនេះ អ្នកតំណាងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ បាននិយាយអំពីបទពិសោធន៍របស់ពួកគេក្នុងនាមជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ នៅក្នុងប្រទេសកម្ពុជា នៅក្នុងកិច្ចពិភាក្សាថ្នាក់ជាតិមួយដែលបានគាំទ្រដោយអង្គការសហប្រជាជាតិ និងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ។ពួកគេជាច្រើនបានចែករំលែករឿងរ៉ាវរបស់ពួកគេអំពីការដែលត្រូវគេបោះបង់ចោល ការបំភិតបំភ័យ និងអំពើហិង្សាពីសំណាក់សមាជិកគ្រួសារ មិត្តភក្តិ និងអាជ្ញាធរមូលដ្ឋាន។ អ្នកខ្លះទៀតបាននិយាយអំពីការរើសអើងដែលបានធ្វើឲ្យពួកគេបោះបង់ចោលការសិក្សា រារាំងពួកគេមិនឲ្យទទួលបានការងារសមរម្យ និងទទួលបានការថែទាំសុខភាព។រឿងរ៉ាវរបស់សិលា[1]ត្រូវបានមនុស្សជាច្រើនដឹងឮ៖

[1] ឈ្មោះពិតរបស់សិលាត្រូវបានផ្លាស់ប្តូរដើម្បីការពារអត្តសញ្ញាណរបស់នាង

No. 53, Pasteur Street, Phnom Penh, Kingdom of CAMBODIA
Tel: +855(0) 23 216 167 / 216 217 | Fax: +855(0)23 210 214 / 721 042 | Website: www.un.org.kh

*"គ្រួសាររបស់ខ្ញុំធ្លាប់តែស្តីបន្ទោសខ្ញុំដោយសារតែអត្តសញ្ញាណរបស់ ខ្ញុំពួកគេប្រមាថមាក់ងាយខ្ញុំនិងមិនចូលចិត្តខ្ញុំ។ ពួកគេក៏ឲ្យខ្ញុំចេញពីផ្ទះផងដែរ...នៅពេលពួកគេឃើញខ្ញុំពាក់ខោអាវស្រី។ នៅសាលារៀនមានបញ្ហាជាច្រើន ហើយមិត្តរួមថ្នាក់មាក់ងាយខ្ញុំ ចំអកឲ្យខ្ញុំ និងគប់ដីសដាក់ខ្ញុំ។គ្រូមិនបានធ្វើអ្វីដើម្បីបញ្ឈប់ពួកគេទេហើយពួកគេមិនចូលចិត្តចរិតរបស់ខ្ញុំដំណើរ និងការនិយាយស្តីរបស់ខ្ញុំទេ។ខ្ញុំរៀនចប់ត្រឹមថ្នាក់ទី៤ប៉ុណ្ណោះ... ខ្ញុំមានការលំបាកច្រើន ដោយសារខ្ញុំមិនដឹងថាតើត្រូវគាំទ្រខ្លួនឯងដូចម្តេច។"*

តាមពិតការទទួលយករបស់គ្រួសារគឺជាការព្រួយបារម្ភចម្បងមួយដែលត្រូវបានលើកឡើង។ដោយប្រឈមមុខនឹងការមាក់ងាយនិងការរើសអើង មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទជាច្រើនត្រូវបង្ខំចិត្តចាកចេញពីគ្រួសាររបស់ពួកគេនៅអាយុក្មេង។ដូចជាសិលាជាដើមជារឿយៗពួកគេងាយរងគ្រោះ ដោយមានឱកាសតិចតួចសម្រាប់ការអប់រំឬការងារ។

ទោះបីជាច្បាប់កម្ពុជាមិនចាត់ទុកជាបទល្មើសដល់ទំនាក់ទំនងភេទដូចគ្នាក្តី ការសិក្សានាពេលថ្មីៗបានរកឃើញថា៖ "មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរមនុស្សប្តូរភេទ ទទួលរងការមាក់ងាយ ការរើសអើង និងការផាត់ចេញពីសង្គមយ៉ាងខ្លាំង នៅតាមទីកន្លែងផ្សេងៗ ដូចជា ផ្ទះ សាលារៀន ទីកន្លែងធ្វើការ មណ្ឌលសុខាភិបាល និងទីកន្លែងសាធារណៈ"។[2] ការរើសអើងបែបនេះធ្វើឲ្យមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ ងាយរងគ្រោះ ហើយ រារាំងពួកគេមិនឲ្យទទួលបានសិទ្ធិពេញលេញរបស់ពួកគេទាំងផ្នែក សង្គម នយោបាយ សេដ្ឋកិច្ច និងវប្បធម៌។ យើងទាំងអស់គ្នារួមមាន អាជ្ញាធររដ្ឋាភិបាលនៅគ្រប់កម្រិតថ្នាក់ ឪពុកម្តាយ គ្រូបង្រៀន និយោជក ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល មានតួនាទីលើកកម្ពស់ និងការពារសិទ្ធិរបស់ មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរមនុស្សប្តូរភេទ ដើម្បីឲ្យពួកគេអាចចូលរួមដោយពេញលេញ និងដោយស្មើភាពនៅក្នុងសង្គមកម្ពុជា។

វិធានការវិជ្ជមានជាច្រើនត្រូវបានចាត់ធ្វើឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ មានការទទួលស្គាល់កាន់តែច្រើនឡើងនូវបញ្ហាទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រក្នុងចំណោមរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍និងអង្គការសង្គមស៊ីវិល។ ព្រះករុណាអតីតព្រះមហាក្សត្រសម្តេច **នរោត្តមសីហនុ** អ្នកនយោបាយ និងមេដឹកនាំសហគមន៍ បានមានព្រះរាជបន្ទូល និងនិយាយជាសាធារណៈប្រឆាំងការរើសអើងនឹងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ។ការរៀបការភេទដូចគ្នាត្រូវបានគាំទ្រដោយមេភូមិជាច្រើនហើយគូស្រករស្រីស្រឡាញ់ ភេទដូចគ្នាចំនួន ១៥គូបានទទួលសំបុត្រអាពាហ៍ពិពាហ៍នៅក្នុងខេត្តកណ្តាល ខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តកំពង់ឆ្នាំង[3]។

---

[2] Vicente S. Salas និង SrornSrun "ការស្វែងយល់ពីការផាត់ចេញពីសង្គមនៃមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ នៅក្នុងគ្រួសារ និងសហគមន៍នៅក្នុងតំបន់ខ្លះនៃកម្ពុជា និងវិធីដោះស្រាយ"ការស្រាវជ្រាវ (ភ្នំពេញ៖ SPCU-CARD Press, 2013)។

[3] Anna Leach "មនុស្សស្រីស្រឡាញ់ភេទដូចគ្នារៀបការស្របតាមច្បាប់ក្នុងប្រទេសកម្ពុជាទោះបីជាពុំមានការផ្លាស់ប្តូរច្បាប់ក៏ដោយ" *Gay Star News*, ៦ ឧសភា ២០១៣, http://www.gaystarnews.com/article/lesbians-legally-married-cambodia-despite-no-law-change060513#sthash.DAgAGVRZ.wGjMYdpn.dpuf.

អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
United Nations in Cambodia

សហគមន៍មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរមនុស្សប្តូរភេទ នៅក្នុងប្រទេសកម្ពុជា កំពុងតែសកម្មខ្លាំងឡើងៗ និងមានការចងក្រងបានល្អ។ សិក្ខាសាលាស្តីពីសិទ្ធិរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរមនុស្សប្តូរភេទ ត្រូវបានធ្វើឡើងជាទៀងទាត់នៅតាមសកលវិទ្យាល័យ ហើយ **សប្តាហ៍មោទនភាព** ត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០០៩មក។ ឆ្នាំនេះ ក្រោមប្រធានបទ "សំឡេងផ្តល់ជូនសហគមន៍ដែលគ្មានសំឡេង" អង្គការនានា ដូចជា*ខាំអាស៊ាន* (CamASEAN) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បណ្តាញបុរសស្រឡាញ់បុរស និងសហគមន៍ឥន្ទធនូកម្ពុជា បានរៀបចំព្រឹត្តិការណ៍ និងសិក្ខាសាលាមួយចំនួន ដែលគ្របដណ្តប់លើបញ្ហានានា ដូចជា ការទទួលយករបស់គ្រួសារ ការការពារផ្នែកច្បាប់ និងមេរោគអេដស៍។ ខ្ញុំសូមកោតសរសើរដល់អង្គការទាំងនេះ ដែលដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការលើកកម្ពស់សិទ្ធិរបស់សហគមន៍ មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ នៅកម្ពុជា។

ចាប់តាំងពីសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលើកទីមួយស្តីពីសិទ្ធិមនុស្ស ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ត្រូវបានអនុម័តក្នុងឆ្នាំ២០១១មក ប្រទេសកាន់តែច្រើនឡើងៗនៅក្នុងទ្វីបអាស៊ី និងជុំវិញពិភពលោក កំពុងតែចាត់វិធានការដើម្បីហាមឃាត់ការរើសអើង ដាក់ទោសបទល្មើសស្អប់ខ្ពើម ទទួលស្គាល់ទំនាក់ទំនងស្នេហារវាងភេទដូចគ្នា និងផ្តល់ឯកសារផ្លូវការដល់មនុស្សប្តូរភេទ និងមនុស្សភេទពីរ។

អង្គការសហប្រជាជាតិកំពុងតែគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ ដោយធ្វើយុទ្ធនាការ "**សេរីភាព និងស្មើភាព**" នៅក្នុងខែកក្កដា ឆ្នាំកន្លងទៅ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សា និងការរើសអើង ព្រមទាំងលើកកម្ពស់សិទ្ធិរបស់មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ។

ការលុបបំបាត់ការរើសអើង ត្រូវការពេលវេលា និងការអប់រំ។ វាតម្រូវឲ្យមានការផ្លាស់ប្តូរ មិនត្រឹមតែច្បាប់ និងគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែបេះដូង និងចិត្តគំនិត ផងដែរ។ យើងគ្រប់គ្នា រួមទាំងរដ្ឋាភិបាល សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងបុគ្គលម្នាក់ៗ អាចចូលរួមនៅក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរទាំងនេះ ដើម្បីប្រឆាំងនឹងអំពើហិង្សា និងការរើសអើងប្រឆាំងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ។ ពីព្រោះថា ពួកគេមានក្តីសុបិន្តដូចគ្នានឹងមនុស្សដទៃទៀតដែរ។

*ក្លែរ វ៉ាន់ ដឺ វ៉ារែន*

*អ្នកសម្របសម្រួលប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ*

*ក្នុងនាមក្រុមប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា*

No. 53, Pasteur Street, Phnom Penh, Kingdom of CAMBODIA
Tel: +855(0) 23 216 167 / 216 217 | Fax: +855(0)23 210 214 / 721 042 | Website: www.un.org.kh